UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

អង្គការសហប្រជាជាតិ
ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

United Nations
Human Rights
OFFICE OF THE HIGH COMMISSIONER FOR HUMAN RIGHTS

# ទិវាសិទ្ធិមនុស្ស

## ភ្នំពេញ ថ្ងៃ ១០ ធ្នូ ២០១០

សន្ទរកថារបស់លោក **គ្រីស្តូហ្វ ប៉េស្ស៊ី**

តំណាងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

មិត្តទាំងឡាយជាទីរាប់អាន,

ថ្ងៃនេះជាឱកាសមួយ ដែលឆ្លុះបញ្ចាំងអំពីសិទ្ធិមនុស្ស តំលៃរបស់សិទ្ធិមនុស្សនៅក្នុងជីវភាពរស់នៅរបស់យើង និងការប្តេជ្ញាចិត្តរបស់យើង ជាបុគ្គល និងជាសមូហភាព ដើម្បីលើកស្ទួយ និងការពារសិទ្ធិមនុស្ស ។

**តើអ្វីទៅជាសិទ្ធិមនុស្ស ?**

ខ្ញុំយល់ថា វាជាការសំខាន់ណាស់ ដើម្បីរំលឹកយើងទាំងអស់គ្នាឲ្យចាំជានិច្ចអំពីថាតើអ្វីទៅជាសិទ្ធិមនុស្ស ជាពិសេស នៅពេលដែលបរិបទទាំងនេះ ជារឿយៗត្រូវបានគេធ្វើឲ្យអាប់អួរ និងយល់ច្រឡំ ដោយការយល់ឃើញខុស ដោយការធ្វើជាមិនដឹងមិនឮ ការមិនអើពើ ឬការជាត់ពណ៌ ភ្ជាប់ទៅនឹងអំពើអាក្រក់ដើម្បីបង្ខូចកិត្យានុភាពសិទ្ធិនេះ។

អ្នកដែលត្រូវគេដកហូតសិទ្ធិមនុស្សជាមូលដ្ឋានបំផុតនោះ ដូចជា សិទ្ធិរស់រានមានជីវិត សិទ្ធិសន្តិសុខបុគ្គល សិទ្ធិនៃសេចក្តីថ្លៃថ្នូរលើរូបកាយ និងបញ្ញាស្មារតី សិទ្ធិសុខភាព សិទ្ធិទទួលបានការអប់រំ សិទ្ធិមានលំនៅដ្ឋាន មានជីវភាពរស់នៅ ឬសិទ្ធិមានការងារ និងមុខរបរ ជាធម្មតា ពួកគាត់យល់អំពីតំលៃនៃសិទ្ធិមនុស្សនៅក្នុងជីវភាពរស់នៅរបស់ខ្លួន ។ កុមារីម្នាក់ដែលត្រូវ បានគេដកហូតសិទ្ធិទទួលបានការអប់រំ ដោយសារតែនាងជាកុមារី ឬជាអ្នកទីទាល់ក្រ តែនាងយល់អំពីតំលៃនៃសិទ្ធិទទួលបានការអប់រំ។ ឪពុកម្នាក់ដែលឃើញកូនរបស់ខ្លួនឈឺជិតស្លាប់ ដោយសារតែគាត់មានជីវភាពក្រីក្រ មិនមានលទ្ធភាពចេញថ្លៃពេទ្យ តែគាត់យល់អំពីតំលៃនៃសិទ្ធិសុខភាព ។ អ្នកកាសែតម្នាក់ដែលជាប់ពន្ធនាគារ ឬត្រូវគេធ្វើឃាត ដោយសារតែការសរសេររបស់ខ្លួន តែគាត់យល់អំពីតំលៃនៃសេរីភាពខាងការសំដែងមតិ និងសេរីភាពខាងសារព័ត៌មាន ។ កសិករម្នាក់ដែលត្រូវបានគេដកហូតដីធ្លីដែលគាត់បានកាប់ឆ្ការ និងបង្ករបង្កើនផលមកជាច្រើនឆ្នាំ តែគាត់យល់អំពីតំលៃនៃសិទ្ធិដីធ្លី ។ កម្មកររោងចក្រម្នាក់ដែលកំពុងតស៊ូជាមួយកម្មករដទៃទៀត ដើម្បីទាមទារឲ្យមានការដំឡើងប្រាក់ឈ្នួល និងលក្ខខណ្ឌការងារល្អប្រសើរ តែគាត់យល់អំពីតំលៃនៃសិទ្ធិបង្កើតសហជីព និងសិទ្ធិធ្វើបាតុកម្មដោយសន្តិវិធី ។ កុមារម្នាក់ដែលឃើញផ្ទាល់ភ្នែកពេលដែលផ្ទះគាត់ត្រូវបំផ្លាញដោយម៉ាស៊ីនឈូសឆាយ ក្រោយមក គាត់ក្លាយជាមនុស្សគ្មានទីជម្រក តែគាត់យល់ដឹងអំពីតំលៃនៃសិទ្ធិដីធ្លី លំនៅដ្ឋាន និងសន្តិសុខ ។

សិទ្ធិមនុស្សឆ្លុះបញ្ចាំងអំពីសេចក្តីប្រាថ្នាដ៏ជ្រាលជ្រៅរបស់មនុស្សគ្រប់រូប ក្នុងការទទួលបានការប្រព្រឹត្តមកលើខ្លួនដោយការគោរពពីអ្នកដទៃ ជាពិសេសពីរដ្ឋ និងដើម្បីទទួលបានជីវភាពរស់នៅពេញលេញ ។ ក្នុងន័យនេះ សិទ្ធិទទួលបានការអភិវឌ្ឍពាក់ព័ន្ធនឹងមនុស្សគ្រប់រូបទាំងអស់ ប្រសិនបើតាមការអភិវឌ្ឍនោះ គេគួរតែយល់ដឹងអំពីមូលហេតុដែលយើងបង្កើតឲ្យមានលក្ខខណ្ឌសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដែលតាមរយៈនោះ យើងអាចទទួលបានជីវភាពរស់នៅដ៏ពេញលេញមួយ។ ដូច្នេះ លុះត្រាណាតែមនុស្សម្នាក់ទទួលបាននូវជីវភាពរស់នៅពេញលេញហើយ នោះទើបជីវិតរបស់គាត់មាន

សុភមង្គល។ សិទ្ធិមនុស្សគឺសំដៅលើសេរីភាព ការគោរព ការសហការ និងការទទួលខុសត្រូវ ។ សិទ្ធិមនុស្សជាតំលៃស្នូលនៃការរស់នៅជាមួយគ្នា ដែលផ្តល់តំលៃដល់ជីវិតបុគ្គល និងសមូហភាព ។ នេះជាមូលហេតុដែលធ្វើឲ្យសិទ្ធិមនុស្សត្រូវបានគេឲ្យតំលៃ និងស្រឡាញ់នៅទូទាំងពិភពលោក ហើយវានឹងបន្តទទួលបានការស្រឡាញ់នៅពេលអនាគតទៅមុខទៀត ដោយសារតែសិទ្ធិមនុស្សផ្តល់គុណតំលៃដល់ជីវិតរបស់យើងគ្រប់រូប។

## តើអ្នកណាជាអ្នកការពារសិទ្ធិមនុស្ស?

អ្នកការពារសិទ្ធិមនុស្សមានប្រភពមកពីគ្រប់ស្រទាប់វណ្ណៈទាំងអស់ ចាប់ពីប្រជាពលរដ្ឋសាមញ្ញដែលការពារដីធ្លី ផ្ទះសម្បែង ផ្នូរបស់បុព្វការីជន សហគមន៍ បរិស្ថាន និងអាជីពរបស់ពួកគេ រហូតដល់ សិស្ស និស្សិត អ្នកសារព័ត៌មាន កម្មករសហជីព វេជ្ជបណ្ឌិត គ្រូបង្រៀន មេធាវី សកម្មជនអង្គការមិនមែនរដ្ឋាភិបាលនានា។ ពួកគេដែលធ្វើសកម្មភាពនៅក្នុងជីវភាពប្រចាំថ្ងៃ នៅក្នុងការងារ និងសង្គមរបស់ខ្លួន ដើម្បីប្រឆាំងទៅនឹងការរើសអើង ការផាត់ចេញ ការគាបសង្កត់ និងអំពើហឹង្សា និងស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះ ក៏ដូចជា គណនីភាពពីសំណាក់ជនទាំងឡាយដែលប្រព្រឹត្តល្មើស ព្រមទាំង តម្លាភាពនៅក្នុងសកម្មភាពរបស់រដ្ឋាភិបាលផងដែរ។

នៅក្នុងបរិបទនេះ អ្នកការពារសិទ្ធិមនុស្សក៏អាចជាមន្ត្រីរដ្ឋាភិបាលផងដែរ ហើយជាបឋមគួរតែជាមន្ត្រីរដ្ឋាភិបាល ព្រោះថាទំនួលខុសត្រូវដំបូងគេបំផុត ក្នុងការលើកស្ទួយ និងការពារសិទ្ធិមនុស្សជាបន្ទុករបស់រដ្ឋាភិបាល។ រដ្ឋមន្ត្រី ឬក៏អភិបាល ដែលអនុញ្ញាតិឲ្យមានការធ្វើបាតុកម្មដោយសន្តិវិធី និងស្របច្បាប់ គឺកំពុងតែដើរតួនាទីជាអ្នកការពារសិទ្ធិមនុស្ស។ វេជ្ជបណ្ឌិតម្នាក់ ដែលជំរុញឲ្យមានការទទួលបាននូវការព្យាបាលជម្ងឺអេដស៍ជាសកលយ៉ាងសកម្មនោះ គឺកំពុងតែដើរតួនាទីជាអ្នកការពារសិទ្ធិមនុស្ស។ ចៅក្រម ដែលអនុវត្តន៍ច្បាប់ដោយយុត្តិធម៌ ក៏ដើរតួនាទីជាអ្នកការពារសិទ្ធិមនុស្សផងដែរ។

ធាតុផ្សំសំខាន់ក្នុងការដើរតួនាទីជាអ្នកការពារសិទ្ធិមនុស្ស គឺជាសម្បជញ្ញៈដែលឲ្យតំលៃលើសិទ្ធិ ការប្តេជ្ញា និងសេចក្តីក្លាហាន។ សេចក្តីក្លាហាន -- ពីព្រោះថា អ្នកការពារសិទ្ធិមនុស្សតែងតែដាក់ជីវិត សុវត្ថិភាពផ្ទាល់ខ្លួននិងក្រុមគ្រួសាររបស់ពួកគេស្ថិតនៅក្នុងហានិភ័យ។ ហេតុដូច្នេះហើយ ទើបពួកគេត្រូវតែទទួលបាននូវកិច្ចការពារ។ ហើយជាបឋម វាគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល ដែលយកចិត្តទុកដាក់អំពីសិទ្ធិមនុស្ស ក្នុងការលើកស្ទួយ និងការពារពួកគេ មិនគ្រាន់តែត្រឹមពាក្យសំដីប៉ុណ្ណោះទេ ប៉ុន្តែសំខាន់បំផុតនោះគឺ ទាំងសកម្មភាពជាក់ស្តែងផងដែរ។ ការទទួលស្គាល់នូវតួនាទីរបស់អ្នកការពារសិទ្ធិមនុស្ស ព្រមទាំងការទទួលខុសត្រូវរបស់រដ្ឋាភិបាល ក្នុងការគោរព ផ្តល់លទ្ធភាព និងការពារពួកគេ ត្រូវបានចរិតនៅក្នុងឆ្នាំ១៩៩៨ ដោយរដ្ឋជាសមាជិកទាំងអស់របស់អង្គការសហប្រជាជាតិ ទៅក្នុងសេចក្តីប្រកាសដែលបានឧទ្ទិសដល់កិច្ចការពាររបស់ពួកគេ ហើយដែលគេស្គាល់ជាទូទៅថាជា "សេចក្តីប្រកាសស្តីពីអ្នកការពារសិទ្ធិមនុស្ស"។

ចំពោះហេតុផលទាំងអស់នេះ ថ្ងៃនេះជាពេលវេលាដ៏សំខាន់ក្នុងការរំលឹកខ្លួនយើងផ្ទាល់អំពីតួនាទី និងការងាររបស់អ្នកការពារសិទ្ធិមនុស្ស មិនត្រឹមតែនៅក្នុងសហគមន៍ ឬប្រទេសរបស់យើងប៉ុណ្ណោះទេ ប៉ុន្តែនៅក្នុងសហគមន៍សកលលោកទាំងមូលផងដែរ និងសូមថ្លែងអំណរគុណជាពិសេសដល់អ្នកការពារសិទ្ធិមនុស្សទាំងអស់ ។ ជាទីបញ្ចប់ ខ្ញុំសូមឲ្យពួកយើងទាំងអស់គ្នានៅថ្ងៃនេះ យកចិត្តទុកដាក់គិតដល់អ្នកដែលត្រូវបានគេដកហូតសិទ្ធិ ត្រូវបានគេដាក់ពន្ធនាគារ ធ្វើទារុណ្ឌកម្ម សម្លាប់ ឬក៏ត្រូវបានគេរំលោភ និងការរើសអើង ពិព្រោះតែការប្រឹងប្រែងដ៏លំបាក ដើម្បីការពារសិទ្ធិរបស់ពួកគេ និងសិទ្ធិរបស់អ្នកដទៃទៀត ដើម្បីធ្វើឲ្យពិភពលោកយើងនេះ បានទៅជាកន្លែងប្រសើឡើងសំរាប់ការរស់នៅ។

សូមអរគុណ